អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០

# សេចក្តីប្រកាសព័ត៌មាន

## អាល្លឺម៉ង់ បានចូលរួមចំណែកផ្តល់ថវិកាចំនួន ១,២ លាន អឺរ៉ូ ដល់ផ្នែកជាតិនៃ អ.វ.ត.ក

រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធរដ្ឋអាល្លឺម៉ង់បានចូលរួមចំណែកថវិកាចំនួន ១,២ លាន អឺរ៉ូ សម្រាប់ គម្រោងលើកកំពស់ការចូលរួមរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក។ ឯកសារគម្រោងនេះ ត្រូវបានចុះហត្ថលេខា នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១០ ដោយនាយក GTZ ប្រចាំនៅតំបន់អាស៊ីខាងត្បូង ឡាវ និង កម្ពុជា និងដោយ ឯកឧត្តម ក្រាញ់ តូនី ប្រធានរដ្ឋបាលស្តីទីនៃ អ.វ.ត.ក នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០។

ថវិការួមចំណែកនេះត្រូវបានផ្តល់ជូនសម្រាប់គម្រោងរយៈពេល ១៦ ខែ គិតចាប់ពីខែកញ្ញា ឆ្នាំ២០១០ ហើយនឹងត្រូវបញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ដោយផ្តោតលើសកម្មភាពនៃការចាត់ចែងលើឯកសារ កម្មវិធី ចុះផ្សព្វផ្សាយ និងការតំណាងតាមផ្លូវច្បាប់នៅចំពោះមុខ អ.វ.ត.ក។ ការចូលរួមរបស់ជនរងគ្រោះគឺជាការងារ មួយក្នុងចំណោមការងារជាច្រើនទៀតដែល អ.វ.ត.ក បានបំបែកឯកត្តកម្ម ហើយបង្កើតជាបទដ្ឋានថ្មីៗសម្រាប់តុលាការទាំងឡាយដែលទទួលការគាំទ្រ និងចូលរួមពីអន្តរជាតិ។ គម្រោងនេះនឹងជួយបន្តជម្រុញឱ្យមានយុត្តិធម៌ និងការផ្សះផ្សាជាតិ តាមរយៈការអនុវត្តន៍សិទ្ធយ៉ាងពេញលេញរបស់ជនរងគ្រោះចំពោះមុខ អ.វ.ត.ក។

ប្រទេសអាល្លឺម៉ង់ គឺជាប្រទេសផ្តល់ជំនួយសំខាន់មួយក្នុងចំណោមបណ្តាប្រទេសផ្តល់ជំនួយដទៃទៀត ដែលផ្តល់ការគាំទ្រដល់ អ.វ.ត.ក ជាហូរហែរមក ចាប់តាំងពីពេលសាលាក្តីនេះត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៦។ ចាប់ពីឆ្នាំ២០០៥រហូតដល់ពេលនេះ ប្រទេសអាល្លឺម៉ង់បានផ្តល់ថវិកាសរុបជាង ៧ លាន អឺរ៉ូ សម្រាប់ទាំងផ្នែកជាតិ និងអន្តរជាតិនៃអ.វ.ត.ក។ នៅក្នុងឆ្នាំ២០១០ ក៏ដូចជាឆ្នាំ២០០៩ ដែរ ប្រទេសអាល្លឺម៉ង់បានផ្តល់ថវិកាចំនួន ១,៥ លាន អឺរ៉ូ ដល់ អ.វ.ត.ក។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក៖

លោក រាជ សម្បត្តិ
ប្រធានកិច្ចការសាធារណ:
ទូរស័ព្ទលេខ៖ +៨៥៥ ១២ ៤៨៨ ១៥៦
ទូរសារលេខ៖+៨៥៥ ២៣ ២១៩ ៨៤១
អ៊ីម៉ែល៖ reach.sambath@eccc.gov.kh

លោក ឌឹម សុវណ្ណារុំ
មន្ត្រីទទួលបន្ទុកកិច្ចការព័ត៌មាន អ.វ.ត.ក
ទូរស័ព្ទលេខ៖ +៨៥៥ ១២ ៤៨៨ ០៩៤
ទូរសារលេខ៖+៨៥៥ ២៣ ២១៩ ៨៤១
អ៊ីម៉ែល៖ dim.sovannarom@eccc.gov.kh

លោកស្រី យូកូ មេដា
មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណ:
ទូរស័ព្ទចល័តលេខ: +855 (0) 12 488 319
ទូរស័ព្ទលេខ: +855 (0) 23 219 814 សារអេឡិចត្រូនិច: maeday@un.org